**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៨២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែប្រែដែនជម្រកសត្វព្រៃកែវសីមា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃកែវសីមា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែដែនជម្រកសត្វព្រៃកែវសីមា ពីផ្ទៃដីទំហំ២៩២ ៦៩០(ពីរសែនប្រាំបួនម៉ឺនពីរពាន់ប្រាំមួយរយកៅសិប)ហិកតា មកផ្ទៃដីទំហំ៣១៧ ៤៥៦(បីសែនមួយម៉ឺនប្រាំពីរពាន់បួនរយហាសិបប្រាំមួយ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរីនិងខេត្តក្រចេះ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS.1984)ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីដែនជម្រកសត្វព្រៃកែវសីមាខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ២៩២ ៦៩០(ពីរសែនប្រាំបួនម៉ឺនពីរពាន់ប្រាំមួយរយកៅសិប)ហិកតា ដែលមានចែងក្នុងអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃកែវសីមា និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះព្រៃស្រែពក ដែលមានផ្ទៃដីទំហំ២៤ ៧៦៦(ពីរម៉ឺនបួនពាន់ប្រាំពីររយហុកសិបប្រាំមួយ)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃ ប្រព័ន្ធអេកូឡូស៊ី និងសារព័នមជ្ឈដ្ឋានធម្មជាតិ ដោយមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ រុក្ខជាតិ និងជីវៈចម្រុះ
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការរស់នៅដោយចីរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃកែវសីមា ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តមណ្ឌលគិរី និងរដ្ឋបាលខេត្តក្រចេះ ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការគ្រប់គ្រងជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមអនុក្រឹត្យស្តីពីការបង្កើតដែនជម្រកសត្វព្រៃកែវសីមា អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣
ផែនទីដែនជម្រកសត្វព្រៃកែវសីមា ស្ថិតក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី និងខេត្តក្រចេះ
ខេត្តមណ្ឌលគិរី
ខេត្តក្រចេះ
សញ្ញាសម្គាល់
ចំណុចនិយាមកា
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ខេត្ត
ព្រំប្រទល់តំបន់ការពារធម្មជាតិ
មាត្រដ្ឋាន 1:350,000
0 7.5 15 km
Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984
ដែនជម្រកសត្វព្រៃកែវសីមា
Google Earth

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

ចំណុចនិយាមកានៃផែនទីដែនជម្រកសត្វព្រៃកែវសីមា

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 758689 | 1387338 | 34 | 691198 | 1351613 | 67 | 688780 | 1383312 |
| 2 | 758342 | 1385473 | 35 | 687755 | 1352064 | 68 | 692447 | 1382985 |
| 3 | 759801 | 1384173 | 36 | 686325 | 1349389 | 69 | 695424 | 1385455 |
| 4 | 759561 | 1382716 | 37 | 683755 | 1347343 | 70 | 699589 | 1386651 |
| 5 | 760039 | 1381291 | 38 | 681203 | 1346338 | 71 | 702114 | 1390550 |
| 6 | 755847 | 1381291 | 39 | 678481 | 1345533 | 72 | 706113 | 1394915 |
| 7 | 751570 | 1381291 | 40 | 675814 | 1343805 | 73 | 707926 | 1392768 |
| 8 | 749483 | 1383556 | 41 | 673482 | 1345386 | 74 | 710326 | 1389395 |
| 9 | 746175 | 1381294 | 42 | 670973 | 1346603 | 75 | 711402 | 1387967 |
| 10 | 745777 | 1384700 | 43 | 669717 | 1345103 | 76 | 714444 | 1386317 |
| 11 | 742126 | 1382715 | 44 | 667555 | 1346821 | 77 | 717133 | 1384743 |
| 12 | 737473 | 1382803 | 45 | 665310 | 1347075 | 78 | 718996 | 1385548 |
| 13 | 732557 | 1381573 | 46 | 663241 | 1349778 | 79 | 721568 | 1384370 |
| 14 | 727361 | 1379733 | 47 | 661154 | 1348376 | 80 | 722609 | 1390273 |
| 15 | 727851 | 1375986 | 48 | 659831 | 1347565 | 81 | 727799 | 1390734 |
| 16 | 732248 | 1374003 | 49 | 657718 | 1345784 | 82 | 731446 | 1393760 |
| 17 | 735580 | 1370493 | 50 | 656884 | 1350311 | 83 | 733478 | 1395217 |
| 18 | 734224 | 1367061 | 51 | 654947 | 1354505 | 84 | 734796 | 1396314 |
| 19 | 734719 | 1363341 | 52 | 652440 | 1359401 | 85 | 735944 | 1398379 |
| 20 | 738413 | 1362365 | 53 | 654330 | 1362604 | 86 | 737549 | 1396639 |
| 21 | 740882 | 1365283 | 54 | 655626 | 1365318 | 87 | 736414 | 1393954 |
| 22 | 744275 | 1365957 | 55 | 659320 | 1365354 | 88 | 738273 | 1393363 |
| 23 | 747917 | 1366905 | 56 | 664797 | 1367908 | 89 | 739305 | 1391948 |
| 24 | 750400 | 1365322 | 57 | 668529 | 1370480 | 90 | 740482 | 1393295 |
| 25 | 749250 | 1363908 | 58 | 670474 | 1374247 | 91 | 742136 | 1389800 |
| 26 | 703259 | 1336562 | 59 | 673720 | 1376252 | 92 | 744577 | 1392423 |
| 27 | 706614 | 1337774 | 60 | 674528 | 1379361 | 93 | 745771 | 1392315 |
| 28 | 707796 | 1341648 | 61 | 676906 | 1380450 | 94 | 749590 | 1392315 |
| 29 | 706513 | 1344959 | 62 | 675925 | 1383896 | 95 | 751095 | 1392796 |
| 30 | 705205 | 1347133 | 63 | 676202 | 1386572 | 96 | 749746 | 1388907 |
| 31 | 701915 | 1349948 | 64 | 679069 | 1386146 | 97 | 751902 | 1387238 |
| 32 | 698629 | 1346997 | 65 | 681937 | 1384815 | 98 | 753010 | 1384888 |
| 33 | 696158 | 1350186 | 66 | 684945 | 1383498 | 99 | 756064 | 1386730 |